ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥ សលរ

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាស "ទិវាសេរីភាពសារព័ត៌មានសកលលោក" លើកទី ៣០
## ថ្ងៃទី ៣ ខែឧសភា ឆ្នាំ២០២៣

បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ ជាទីស្រឡាញ់រាប់អាន!

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ សូមចូលរួមអបអរសាទរជាមួយបងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ក្នុងឱកាស "ទិវាសេរីភាពសារព័ត៌មានសកលលោក" លើកទី៣០ ដែលពិធីនេះតែងតែប្រារព្ធឡើងនាថ្ងៃទី៣ ខែឧសភា ជារៀងរាល់ឆ្នាំ ដើម្បីលើកស្ទួយសិទ្ធិ សេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិ។ ទិវាសេរីភាពសារព័ត៌មានសកលលោកលើកទី៣០ ឆ្នាំ២០២៣នេះ គាប់ជួនត្រូវជាមួយនឹងខួបទី៣០ នៃសន្និសីទក្រុងវីយែន និងសេចក្តីប្រកាសស្តីពីកម្មវិធីសកម្មភាពសិទ្ធិមនុស្ស និងខួបលើកទី៧៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលធ្វើឱ្យទិវានេះកាន់តែមានសារសំខាន់ថែមទៀតក្នុងការគាំពារសិទ្ធិ សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពខាងសារព័ត៌មាននៅទូទាំងសកលលោក។

ទិវាសេរីភាពសារព័ត៌មានសកលលោកឆ្នាំ២០២៣នេះ បានលើកយកប្រធានបទស្តីពី "**ការកំណត់អនាគតនៃសិទ្ធិ៖** សេរីភាពនៃការបញ្ចេញមតិជាកម្លាំងចលករនៃសិទ្ធិមនុស្សដទៃទៀត" ស្របពេលដែលពិភពលោកទាំងមូលកំពុងជួបប្រទះវិបត្តិនយោបាយ និងសេដ្ឋកិច្ចសកល បង្កឱ្យកើតមានបញ្ហាជាច្រើនដូចជា ជម្លោះប្រដាប់អាវុធ អំពើហិង្សា ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ការអនុវត្តស្តង់ដាពីរទូវសិទ្ធិ សេរីភាពនៃការបញ្ចេញមតិតាមរយៈការបិទប្រព័ន្ធផ្សព្វផ្សាយរុស្សីពីសំណាក់លោកខាងលិច ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិមនុស្ស វិសមភាពប្រតិបត្តិការពាណិជ្ជកម្មសកល សេរីភាពនៃការបញ្ចេញមតិ ការធ្វើចំណាកស្រុក និងបញ្ហាប្រឈមជាច្រើនទៀតរបស់ប្រជាជននៅទូទាំងសកលលោក ព្រមទាំងការរីករាលដាលនៃព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ ដែលធ្វើប៉ះពាល់ដល់កិត្តិយស និងសិទ្ធិបុគ្គលឯកជន សិទ្ធិប្រជាធិបតេយ្យ ដែលទាមទារឱ្យស្ថាប័នអន្តរជាតិ ស្ថាប័នរដ្ឋ ស្ថាប័នសារព័ត៌មាន

អ្នកសារព័ត៌មាន និងដៃគូពាក់ព័ន្ធទាំងអស់ស្វែងរកដំណោះស្រាយរួមគ្នា ដើម្បីធានាបាននូវសេរីភាពសារព័ត៌មាន និងសេរីភាពនៃការបញ្ចេញមតិប្រកបដោយចីរភាពសម្រាប់សកលលោកទាំងមូល។

**បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជាទីស្រឡាញ់!**

ទៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះ និងវាយតម្លៃខ្ពស់ចំពោះស្ថាប័នសារព័ត៌មាន និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលបានខិតខំរួមចំណែកក្នុងការបំពេញការងារជូនប្រទេសជាតិនាពេលកន្លងមក ទោះបីរងផលប៉ះពាល់នៃវិបត្តិនយោបាយសកល វិបត្តិនៃការធ្លងរីករាលដាលនៃជំងឺកូវីដ-១៩ និងវិបត្តិសេដ្ឋកិច្ចសកល ក៏បងប្អូនអ្នកសារព័ត៌មានបានខិតខំពុះពារជំនះរាល់ឧបសគ្គក្នុងការស្វែងរកព័ត៌មាន ដែលបានកើតឡើងទាំងនៅក្នុងប្រទេស និងនៅលើសកលលោក ដើម្បីធ្វើការចែករំលែក និងផ្សព្វផ្សាយជូនសាធារណជនបានជ្រួតជ្រាបយល់ដឹងអំពីបញ្ហានយោបាយសេដ្ឋកិច្ច សង្គម និងបញ្ហាផ្សេងៗទៀតដែលទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃរបស់ពួកគេបានរហ័សទាន់សភាពការណ៍ ដែលធ្វើឱ្យព័ត៌មានទាំងឡាយនៅលើសកលលោកស្ថិតនៅលើម្រាមដៃរបស់មនុស្សក្នុងយុគសម័យបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។

ខ្ញុំសូមយកឱកាសនេះបញ្ជាក់ជូនជាថ្មីម្តងទៀតថា រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តការប្តេជ្ញាចិត្តក្នុងការគាំពារសិទ្ធិ សេរីភាពនៃការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីរបបសារព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការប្តេជ្ញាចិត្តនេះបានធ្វើឱ្យវិស័យសារព័ត៌មាននៅព្រះរាជាណាចក្រកម្ពុជា មានការរីកចម្រើនគួរជាទីមោទនៈដោយមធ្យោបាយនៃប្រព័ន្ធផ្សព្វផ្សាយកាន់តែទំនើប និងសម្បូរបែបដែលអាចឱ្យប្រជាពលរដ្ឋទាំងក្នុង និងក្រៅប្រទេសបានទទួលព័ត៌មានយ៉ាងទូលំទូលាយទាន់ពេលវេលា និងគ្រប់ទីកន្លែង។ទន្ទឹមនឹងការរីកចម្រើននៃប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងបរិមាណអង្គភាពសារព័ត៌មាន ព្រមទាំងអ្នកសារព័ត៌មានដ៏ច្រើនលើសលប់នៅក្នុងប្រទេសកម្ពុជា នាពេលបច្ចុប្បន្ន ក៏យើងត្រូវគិតគូរអំពីគុណភាព និងការទទួលខុសត្រូវរបស់អ្នកសារព័ត៌មានផងដែរ។ ព្រោះប្រព័ន្ធផ្សព្វផ្សាយ ជាអាវុធមុខពីរដែលធ្វើឱ្យប្រទេសជាតិមានការរីកចម្រើនតាមរយៈការចូលរួមរបស់អ្នកសារព័ត៌មាន ក្នុងការអភិវឌ្ឍប្រទេសជាតិ ការថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយដែលធ្វើឱ្យប្រទេសជាតិមានការរីកចម្រើន ហើយប្រព័ន្ធផ្សព្វផ្សាយក៏អាចធ្វើឱ្យប្រទេសជាតិជួបប្រទះភាពចលាចល វឹកវរ នៅក្នុងសង្គមតាមរយៈការផ្សាយព័ត៌មានមិនពិត ព័ត៌មានក្លែងក្លាយ និងព័ត៌មានញុះញង់បំពុលសង្គមដែលអាចធ្វើឱ្យប្រទេសជាតិអន្តរាយ ដែលទាមទារឱ្យយើងទាំងអស់គ្នា ជាពិសេសស្ថាប័ន ព័ត៌មាន និងអ្នកសារព័ត៌មានត្រូវតែចូលរួមប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត ព័ត៌មានក្លែងក្លាយ ព័ត៌មានញុះញង់ដែលបង្កឡើងដោយក្រុមឱកាសនិយមមួយក្តាប់តូច និងជនខិលខូចជ្រកក្រោមស្លាកសារព័ត៌មានដើម្បីបំរើផលប្រយោជន៍ផ្ទាល់ខ្លួន ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ប្រទេសជាតិជាតិ និងកិត្តិយស សេចក្តីថ្លៃថ្នូររបស់អ្នកសារព័ត៌មាន និងស្ថាប័នសារព័ត៌មានទាំងមូល។



https://t.me/oa_channel

ទៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមបញ្ជាក់ជូនបងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ថា នៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣ កម្ពុជានឹងរៀបចំពិធីបើកការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ខ្ញុំសូមអំពាវនាវដល់បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលនឹងចូលរួមបំពេញការងារក្នុងព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ សូមឱ្យគោរពតាមក្រមសីលធម៌ វិជ្ជាជីវៈ បទបញ្ជា និងបទប្បញ្ញត្តិរបស់គណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ ឆ្នាំ២០២៣ និងមានការទទួលខុសត្រូវខ្ពស់ក្នុងការចូលយកព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន ដោយរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយនៅតាមទីលានប្រកួត និងតាមទីតាំងផ្សេងៗ ដើម្បីឱ្យការរៀបចំការប្រកួតបានប្រព្រឹត្តិទៅដោយភាពល្អ គ្មានការរំខានដល់ការប្រកួត និងចូលរួមផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ដែលរាជរដ្ឋាភិបាលបានផ្តល់សិទ្ធិជូនប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិធ្វើការផ្សព្វផ្សាយដោយឥតគិតថ្លៃ និងចូលទស្សនាព្រឹត្តិការណ៍ពិធីបើក-បិទ និងការប្រកួតកីឡាស៊ីហ្គេម ឆ្នាំ២០២៣ ដោយឥតគិតថ្លៃ។

មុននឹងបញ្ចប់ ខ្ញុំក៏សូមអំពាវនាវដល់បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលកំពុងបំពេញបេសកកម្មលើវិស័យព័ត៌មានទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងនៅលើសកលលោក សូមយកចិត្តទុកដាក់អនុវត្តការកិច្ចឱ្យបានត្រឹមត្រូវតាមក្រមសីលធម៌ វិជ្ជាជីវៈ និងខិតខំអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ទាំងផ្នែកជំនាញបច្ចេកទេស ទាំងការផលិត និងផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្កើនជំនឿទុកចិត្តដល់សាធារណជន និងឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឌីជីថល ដើម្បីធ្វើការប្រកួតប្រជែងទីផ្សារឱ្យមានសក្តានុពលថែមទៀតចៀសវាងការផ្សាយព័ត៌មានបំភ្លៃការពិតដែលធ្វើឱ្យសាធារណជនបាត់បង់ជំនឿ និងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសសេចក្តីថ្លៃថ្នូររបស់អ្នកសារព័ត៌មាន និងតម្លៃរបស់ស្ថាប័នសារព័ត៌មានទាំងមូល។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរបងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ទាំងអស់ ទទួលបានជោគជ័យក្នុងការបំពេញការកិច្ចរបស់ខ្លួន និងសូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសៅរ៍ ១០កើត ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**